# មហាវិទ្យាល័យតូរ្យតន្ត្រី

## ១.ស្ថានភាពទូទៅ

មហាវិទ្យាល័យតូរ្យតន្ត្រីគឺជាផ្នែកមួយនៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈមានកាតព្វកិច្ចបណ្តុះបណ្តាលឯកទេសតូរ្យតន្ត្រីកំរិតឧត្តមសិក្សា។ កម្មវិធីសិក្សារបស់មហាវិទ្យាល័យតូរ្យតន្ត្រី ផ្តោតសំខាន់ទៅលើការបណ្តុះបណ្តាលឧបករណ៍តន្ត្រីបុរាណខ្មែរ ឧបករណ៍តន្ត្រីបស្ចិមប្រទេស ចម្រៀងបុរាណចម្រៀងជាពួក ចម្រៀងអូប៉េរ៉ា និពន្ធតន្ត្រី បញ្ជារវង់ភ្លេង និងជាតិពន្ធុតន្ត្រីវិទ្យា ។ល។ ការសិក្សាមានរយៈពេលបួនឆ្នាំះ ឆ្នាំទី១(ថ្នាក់ឆ្នាំមូលដ្ឋាន)សិក្សានៅដេប៉ាដឺម៉ង់ថ្នាក់ឆ្នាំមូលដ្ឋាន ឆ្នាំទីពីរ ទីបី និងទីបួនសិក្សានៅមហាវិទ្យាល័យតូរ្យតន្ត្រី។

ដើម្បីចូលរួមចំណែកកសាងធនធានមនុស្សក្នុងវិស័យសិល្បៈវប្បធម៌ខ្មែរ មហាវិទ្យាល័យតូរ្យតន្ត្រីកំពុងបណ្តុះបណ្តាលនិស្សិតឲ្យក្លាយទៅជាអ្នកមានទេពកោសល្យច្នៃប្រឌិត នឹងបង្កើតស្នាដៃសិល្បៈតន្ត្រីគ្រប់ទំរង់ ប្រកបដោយគុណភាព សមត្ថភាព និងប្រសិទ្ធភាព។

រាល់ដំណើរការនៃសកម្មភាពទាំងអស់ដែលទាក់ទងទៅនឹងកម្មវិធីសិក្សា គឺមានការទទួលស្គាល់និងវាយតម្លៃពីក្រសួងអប់រំយុវជននិងកីឡា គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា និងរាជរដ្ឋាភិបាលកម្ពុជាក្នុងន័យសហប្រតិបត្តិការល្អមានលក្ខណៈនិយាម(ស្តង់ដា)ជាតិ តំបន់ និងអន្តរជាតិ

សិក្សានៅមហាវិទ្យាល័យតូរ្យតន្ត្រី និស្សិតគ្រប់ៗរូប អាចទទួលបានចំណេះដឹងយ៉ាងទូលំទូលាយពីសាស្ត្រាចារ្យខ្មែរ និងបរទេស ដែលមានបទពិសោធន៍ជាច្រើនឆ្នាំព្រមទាំងមានការគាំទ្រពីគ្រប់មជ្ឈដ្ឋានដែលជាអាទិភាពក្នុងការអភិវឌ្ឍន៍ធនធានមនុស្សប្រកបដោយគុណភាពខ្ពស់។

ពេលបញ្ចប់ការសិក្សា និស្សិតនឹងក្លាយជាតន្ត្រីករអាជីព ដែលមានសមត្ថភាពគ្រប់គ្រាន់ដើម្បីរួមចំណែកក្នុងការថែរក្សា ការពារ  និងលើកស្ទួយតម្លៃសិល្បៈវប្បធម៌ជាតិ អត្តសញ្ញាណជាតិ ឈរលើ មូលដ្ឋាននៃការអភិរក្ស និងអភិវឌ្ឍន៍សមស្របទៅតាមដំណើរការនៃសាកលភាវូបនីយកម្ម។

## ២. ប្រវត្តមហាវិទ្យាល័យតូរ្យតន្ត្រី

មហាវិទ្យាល័យតូរ្យតន្ត្រីបានវិវឌ្ឍន៍មកពីសាលាជាតិតូរ្យតន្ត្រី ដែលមានគេស្គាល់តាំងពីឆ្នាំ ១៩៥៩ កាលនោះមានទីតាំងនៅម៉ុំក្រោយពេទ្យចិន ក្រោយមកសាលាបានប្តូរមកនៅម៉ុំទួលគោកនៅឆ្នាំ ១៩៩២។ ចាប់ពីសាលាតូរ្យតន្ត្រី បានបើកដំណើរការមក សាលាបានជ្រើសរើសសិស្ស ឲ្យចូលរៀនជាមួយគ្រូភ្លេង ដែលភាគច្រើនជាគ្រូជនជាតិបរទេស (ជនជាតិអាឡឺម៉ង់) ក្រោយមកសិស្សដែល ទទួលបានការបណ្តុះ បណ្តាលរួច បានក្លាយខ្លួនជាគ្រូតន្ត្រី និងចម្រៀងនៅសាលានោះ។

កម្មវិធីសិក្សារួមមាន  អក្សរសាស្ត្រ គណិតវិទ្យា ទ្រឹស្តីជុំវិញសិល្បៈ អក្សរភ្លេង ប្រវត្តិតន្ត្រីអាគូស្ទីក ស្ទីក ទ្រឹស្តីតន្ត្រី និងភាសាបារាំង។ ឯកទេសរួមមាន៖ ព្យាណូ វីយូឡុង វីយូឡា វីយូឡុងសែល កុងត្រឹបាស់ ហ្លូត ក្លារីណែត ត្រុំប៉ែត ត្រុំបោន និងចម្រៀងជាពួក។ ដល់ឆ្នាំ១៩៦៧ វង់តន្ត្រីសាំហ្វូនី មួយក៏បានបង្កើត ឡើងដោយមានការជ្រោមជ្រែងពីសំណាក់លោកសាស្ត្រាចារ្យ ម៉ូរីស លីយេបូ ជាជនជាតិបារាំង និងមាន លោក ម៉ិល សុផុន ជាអ្នកបង្ហាត់ និងបញ្ជាវង់ភ្លេងនេះរហូតដល់ ឆ្នាំ១៩៧៥។

ដោយឡែក សាលាតូរ្យតន្ត្រីបុរាណ បានបង្កើតឡើងនៅឆ្នាំ ១៩៦៣ ដែលជាផ្នែកមួយនៃសាលា របាំ និងល្ខោន មានទីតាំងនៅមុំទីស្តីការគណៈរដ្ឋមន្ត្រីបច្ចុប្បន្ន។ វង់តន្ត្រីចម្រុះត្រូវបានបង្កើត ឡើងនៅឆ្នាំ ១៩៦៥ ដែលមានឧបករណ៍តន្ត្រីបុរាណខ្មែរ និងឧបករណ៍តន្ត្រីបច្ចឹមប្រទេសប្រគុំរួមគ្នា ដោយចាប់ផ្តើម ប្រើប្រាស់អក្សរភ្លេងផងដែរ។

អំឡុងឆ្នាំ ១៩៧៥-១៩៧៩សាលាតូរ្យតន្ត្រីបានបិទទ្វារទាំងស្រុង។ នៅឆ្នាំ១៩៨០យោងតាមសេច-ក្តីសំរេចលេខ ៨៦/៨០ ចុះថ្ងៃទី ០៩ ខែឧសភា សាលាវិចិត្រសិល្បៈ បានបើកឲ្យដំណើរការឡើងវិញ ក្នុង នោះមានផ្នែកតូរ្យតន្ត្រី របាំ សៀក ល្ខោននិងផ្នែកសូនរូប ដែលមានទីតាំងនៅក្នុងសាកលវិទ្យាល័យភូមិន្ទ វិចិត្រសិល្បៈបច្ចុប្បន្ន។ ចាប់តាំងពីនោះមក សាលាមានកម្មវិធីបណ្តុះបណ្តាលទាំងតន្ត្រីបុរាណខ្មែរ និង តន្ត្រីបច្ចឹមប្រទេសរួមមាន៖ ឯកទេស ទ្រឹស្តីតន្ត្រី ទ្រឹស្តីសិល្បៈ ព្រមទាំងមុខវិជ្ជាចំណេះទូទៅស្របតាមកម្ម វិធីសិក្សារបស់ក្រសួងអប់រំ ក្រោមការ បង្ហាត់បង្រៀនពីគ្រូខ្មែរ និងគ្រូបរទេស។

យោងតាមអនុក្រឹត្យលេខ ៤៧  អនក្រ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៨៨ សាកលវិទ្យាល័យ វិចិត្រ សិល្បៈបានបង្កើតឡើងរួមមាន៖ មហាវិទ្យាល័យតូរ្យតន្ត្រី មហាវិទ្យាល័យសិល្បៈសូនរូប មហាវិទ្យាល័យ សិល្បៈនាដសាស្ត្រ មហាវិទ្យាល័យបុរាណវិទ្យា និងមហាវិទ្យាល័យស្ថាបត្យកម្ម និងនគរពោបនីយវិទ្យា។ មហាវិទ្យាល័យតូរ្យតន្ត្រីមានកម្មវិធីសិក្សាចាប់ពីកម្រិតបឋម មធ្យម ដោយឡែកកម្រិតឧត្តមសិក្សាមាន ពីរឯកទេស គឺ៖ ឯកទេសនិពន្ធតន្ត្រី និងជាតិពន្ធុតន្ត្រីវិទ្យា ដែល មានទីតាំងនៅខាងលិចជាប់ស្តាតចាស់ (អតីតសាលាយុវជន ស្រោចស្រង់ជាតិ)។

នៅឆ្នាំសិក្សា១៩៩២-១៩៩៣ មហាវិទ្យាល័យតូរ្យតន្ត្រីត្រូវបានផ្អាកការបណ្តុះបណ្តាលឯកទេស និពន្ធតន្ត្រី ដោយសារខ្វះធនធានសាស្ត្រាចារ្យ មានតែឯកទេសជាតិពន្ធុតន្ត្រីវិទ្យាប៉ុណ្ណោះ ដែលអាចបន្ត បាន។

នៅឆ្នាំ១៩៩៨ មហាវិទ្យាល័យបានចាប់ផ្តើមបើកទទួលនិស្សិតឲ្យចូលរៀនថ្នាក់ឧត្តមសិក្សា ឡើង វិញលើគ្រប់ឯកទេស ដោយមានការចូលរួមពីអតីតនិស្សិតបានបញ្ចប់ការសិក្សាក្នុងស្រុក ពីបរទេសនិង

សាស្ត្រាចារ្យជនជាតិបរទេសមានកម្រិតសញ្ញាបត្របណ្ឌិត បរិញ្ញាបត្រជាន់ខ្ពស់និងបរិញ្ញាបត្រ ព្រមទាំងព្រឹទ្ធាចារ្យដែលមានបទពិសោធន៍ផ្នែកតន្ត្រី។ បច្ចុប្បន្ននេះមហាវិទ្យាល័យ តូរ្យតន្ត្រីមានទីតាំងនៅក្នុងបរិវេណនៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ។

នៅឆ្នាំ២០០៥សកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈត្រូវបានក្លាយជាគ្រឹះស្ថានសាធារណៈរដ្ឋបាល។ ចាប់ពីនោះមកមហាវិទ្យាល័យតូរ្យតន្ត្រីបណ្តុះបណ្តាលតែកម្រិតឧត្តមសិក្សា ថ្នាក់បរិញ្ញាបត្រតែប៉ុណ្ណោះ

ឈ្មោះអ្នកគ្រប់គ្រងសាលាតូរ្យតន្ត្រី និងមហាវិទ្យាល័យចាប់ពីឆ្នាំ១៩៥៩ មាន៖

១- លោក ជា មុយ (ឆ្នាំ១៩៥៩-១៩៦២) ជានាយក

២- លោក មាស ឡាវ (ឆ្នាំ១៩៦២-១៩៦៣) ជានាយក

៣- លោក ម៉ម បូផានី (ឆ្នាំ១៩៦៣-១៩៧៥) ជានាយក

៤- លោក ឃួន ចន (ឆ្នាំ១៩៨០-១៩៨១) ជានាយក

៥- លោក ហ៊ុន សារិន (ឆ្នាំ១៩៨១-១៩៨៨) ជានាយក

៥. លោក លោក ប៊ិន ហុងផាត (១៩៨៨-១៩៨៩) ជាព្រឹទ្ធបុរស

៥- លោក ហ៊ុន សារិន (ឆ្នាំ១៩៨៩-១៩៩៤) ជាព្រឹទ្ធបុរស

៦- លោក វ៉ែន ផាត (ឆ្នាំ១៩៩៤-២០០៨) ជាព្រឹទ្ធបុរស

៧- លោក យស ច័ន្ទដារ៉ា (ឆ្នាំ២០០៩ ដល់បច្ចុប្បន្ន) ជាព្រឹទ្ធបុរស។

## ៣. អំពីសាស្ត្រាចារ្យ និងថ្នាក់ដឹករបស់មហាវិទ្យាល័យតូរ្យតន្ត្រី

មហាវិទ្យាល័យតូរ្យតន្ត្រីមានសាស្ត្រាចារ្យសរុបចំនួន ៤០ រូប ( ស្ត្រី១៤ ) ៖

- សាស្ត្រាចារ្យផ្ទៃក្នុងចំនួន ១៩ រូប ( ស្ត្រី៨ )
- សាស្ត្រាចារ្យអញ្ជើញ ចំនួន ១៨ រូប (ស្ត្រី០៥) ក្នុងនោះមានសាស្ត្រាចារ្យបរទេសចំនួន ៣ រូប (ស្ត្រី០១) ។

- ថ្នាក់ដឹកនាំរួមមាន៖ ព្រឹទ្ធបុរសមួយរូប និងព្រឹទ្ធបុរសរងចំនួនបីរូប ( ស្ត្រី១ )។
- មន្ត្រីរដ្ឋបាលចំនួនចំនួន ១២ រូប ( ស្ត្រី០៥ ) ក្នុងនោះមាន៖
- លេខាធិការចំនួន ០១ រូប ( ជាស្ត្រី )
- ភ្នាក់ងាររដ្ឋបាលចំនួន ០១ រូប ( ជាស្ត្រី )
- មន្ត្រីគ្រប់គ្រងរដ្ឋបាលចំនួន ០៥ រូប ( ស្ត្រី០២ )
- មន្ត្រីកម្មសិក្សាចំនួន ០១ រូប

## ៤. រចនាសម្ព័ន្ធគ្រប់គ្រងនៅមហាវិទ្យាល័យតូរ្យតន្ត្រី



**លោក ហង្ស រិទ្ធីរ៉ាវុធ**

*ព្រឹទ្ធបុរសស្តីទី*



**លោក ប៉ែន សំអុល**

*ព្រឹទ្ធបុរសរង ទទួលបន្ទុក កិច្ចការរដ្ឋបាល*



**កញ្ញា ម៉ៅ ឡេណា**

*ព្រឹទ្ធបុរសរង ទទួលបន្ទុក ការងារសិក្សា*



*អ្នកស្រី ភី លក្ខិណា*

*លេខា*



*កញ្ញា ស៊ុំ ស៊ុថា*

*ភ្នាក់ងាររដ្ឋបាល*

## មន្ត្រីគ្រប់គ្រងរដ្ឋបាល


- លោក សួន ផល្លី


- កញ្ញា កែម ចន្ទូ


-កញ្ញា ស៊ិន សុភា


-លោក ចែម សំអឿន


- លោក វី ដីវ័ន្ត


- លោក មាស សុគន្ធ

## សាស្ត្រាចារ្យប្រចាំមហាវិទ្យាល័យតូរ្យតន្ត្រី


- លោក ច័ន្ទ វិត្ថារ៉ូ


- លោកស្រី កែវ សិរីវណ្ណា


- លោក ហួត ធា


- លោកស្រី កែវ សុខគីម


- លោក កែវ ច័ន្ទធារី


- លោក ថូ ប៊ុនតាភវុធ


- លោក កែវ ដូរីវណ្ណ


- លោក កែវ សុភី


- លោក កែវ សុនន្ទករី


- លោក សោម ណាត្រី


- លោក វ៉ែន ហាដាន់


- លោក ហ៊ុយ ស្រៀង


- លោក ហៀង សុផន


- លោក សោម សុធី


- លោក វ៉ែន ផាថេត


- កញ្ញា ង៉ន ស៊ីវ៉ានី


- លោក កែម រិទ្ធី


- លោក ហ៊ិន ចំរើន

## សាស្ត្រាចារ្យបរទេស


- *Dr.* Ki Yong, RYU*(S.Korea)*

Professor of vocal/advisor


- *Mrs.* Ji Young, SEO*(S.Korea)*

Assist professor of vocal


- *Dr. George Hess(Singapure)*

Associate professor of Guitar

## ៥. អំពីឯកទេសនៅមហាវិទ្យាល័យតន្ត្រី

*តារាងឯកទេសនៅមហាវិទ្យាល័យតន្ត្រី ៖*

| ១. តន្ត្រីបុរាណ Traditional Music | | | ២. តន្ត្រីបស្ចិមប្រទេស Western Music | | |
|---|---|---|---|---|---|
| ល.រ | ឯកទេស | Specialties | ល.រ | ឯកទេស | Specialties |
| ០១ | រនាតឯក | RoneatEk | ០១ | ចម្រៀងសូប្រាណូ | Soprano |
| ០២ | រនាតធុង | Roneat Thong | ០២ | ចម្រៀងអាល់តូ | Alto |
| ០៣ | រនាតថោង | RoneatThaong | ០៣ | ចម្រៀងតេន័រ | Tenor |
| ០៤ | គងវង់តូច | Kong Vong Touch | ០៤ | ចម្រៀងបារីតុង | Baritone |
| ០៥ | គងវង់ធំ | Kong vong Thom | ០៥ | វីយូឡុង | Violin |
| ០៦ | ស្គរបុរាណ | traditional drums | ០៦ | វីយូឡា | Viola |
| ០៧ | ទ្រសោ | Tro-Sao | ០៧ | សែលឡូ | Cello |
| ០៨ | ទ្រអ៊ូ | Tro-Ou | ០៨ | កុងត្រឺបាស់ | Double Bass |
| ០៩ | ទ្រខ្មែរ | Tro-Khmer | ០៩ | ព្យាណូ | Piano |
| ១០ | តាខេ | Takhe | ១០ | ហ្លូត | Flute |
| ១១ | ឃឹម | Khim | ១១ | ក្លារីណែត | Clarinet |
| ១២ | ខ្សែដៀវ | Kse-Deav | ១២ | សាក់សូហ្វូន | Saxophone |
| ១៣ | ខ្លុយ | Khloy | ១៣ | ត្រុំប៉ែត | Trumpet |
| ១៤ | ស្រឡៃ | Srolay | ១៤ | ស្គរសម័យ | Drums set |
| ១៥ | ប៉ីអ | Pei-Or | ១៥ | និពន្ធតន្ត្រី | Composition |
| ១៦ | ចាប៉ីដងវែង | Chapey-Dorngveng | ១៦ | បញ្ជាវង់ភ្លេង | Conducting |
| ១៧ | ចម្រៀងអាយ៉ៃ | Ayai Song | ១៧ | បញ្ជាចម្រៀងជាពួក | Choir Conducting |
| ១៨ | ចម្រៀងមហោរី | Mohory Singing | ១៨ | ជាតិពន្ធុតន្ត្រីវិទ្យា | Ethnomusicology |
| ១៩ | ចម្រៀងភ្លេងការ | Weeding Singing | ១៩ | តន្ត្រីវិទ្យា | Musicology |
| | | | ២០ | ទ្រឹស្តីតន្ត្រី | Theory of Music |

- មហាវិទ្យាល័យនឹងបញ្ចូលមុខវិជ្ជាឯកទេសមួយចំនួនទៀតតាមការចាំបាច់។

**តារាងមុខវិជ្ជាជ្រើសរើស ៖

| ១. តន្ត្រីបុរាណ Traditional Music | | | ២. តន្ត្រីបស្ចឹមប្រទេស Western Music | | |
|---|---|---|---|---|---|
| ល.រ | ឯកទេស | Specialties | ល.រ | ឯកទេស | Specialties |
| ០១ | រនាតឯក | RoneatEk | ០១ | ចម្រៀងសូប្រាណូ | Soprano |
| ០២ | រនាតធុង | Roneat Thong | ០២ | ចម្រៀងអាល់តូ | Alto |
| ០៣ | រនាតថោង | RoneatThaong | ០៣ | ចម្រៀងតេន័រ | Tenor |
| ០៤ | គងវង់តូច | Kong Vong Touch | ០៤ | ចម្រៀងបារីតុង | Baritone |
| ០៥ | គងវង់ធំ | Kong vong Thom | ០៥ | វីយូឡុង | Violin |
| ០៦ | ស្គរបុរាណ | traditional drums | ០៦ | វីយូឡា | Viola |
| ០៧ | ទ្រសោ | Tro-Sao | ០៧ | សែលឡូ | Cello |
| ០៨ | ទ្រអ៊ូ | Tro-Ou | ០៨ | កុងត្រឹបាស់ | Double Bass |
| ០៩ | ទ្រខ្មែរ | Tro-Khmer | ០៩ | ព្យាណូ | Piano |
| ១០ | តាខេ | Takhe | ១០ | ហ្លូត | Flute |
| ១១ | ឃឹម | Khim | ១១ | ក្លារីណែត | Clarinet |
| ១២ | ខ្សែដៀវ | Kse-Deav | ១២ | សាក់សូហ្វូន | Saxophone |
| ១៣ | ខ្លុយ | Khloy | ១៣ | ត្រុំប៉ែត | Trumpet |
| ១៤ | ស្រឡៃ | Srolay | ១៤ | ស្គរសម័យ | Drums set |
| ១៥ | ប៉ីអ | Pei-Or | | | |
| ១៦ | ចាប៉ីដងវែង | Chapey-Dorngveng | | | |
| ១៧ | ចម្រៀងអាយ៉ៃ | Ayai Song | | | |
| ១៨ | ចម្រៀងមហោរី | Mohory Singing | | | |
| ១៩ | ចម្រៀងភ្លេងការ | Weeding Singing | | | |
| | | | | | |

## ៦. កម្មវិធីសិក្សានៅមហាវិទ្យាល័យតន្ត្រី

កម្មវិធីសិក្សានៅមហាវិទ្យាល័យតន្ត្រីមានបួនឆ្នាំសិក្សាគឺៈ

១. ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន(ឆ្នាំទី១)និស្សិតទាំងអស់ទទួលការបណ្តុះបណ្តាលលើមុខវិជ្ជាមូលដ្ឋាន ចំនួនប្រាំវិស័យគឺ ៈ

- សិល្បៈ និងមនុស្សសាស្ត្រ
- គណិតវិទ្យា វិទ្យាសាស្ត្រ
- វិទ្យាសាស្ត្រសង្គម
- ភាសារបរទេស
- តម្រង់ទិសជំនាញ ។

២. ថ្នាក់ឆ្នាំទីពីរ និងទីបី និស្សិតទាំងអស់ទទួលបាននូវការពង្រឹងចំណេះដឹងទាំងឯកទេស ទាំងទ្រឹស្តី ដើម្បីបង្កើននូវសមត្ថភាពប្រគំតន្ត្រី ច្រៀង និពន្ធតន្ត្រី បញ្ជារវង់ភ្លេង ក៏ដូចជាការសិក្សាស្រាវជ្រាវតន្ត្រី ដែលជាទុនសម្រាប់ការប្រឡងបញ្ចប់បរិញ្ញាបត្រនាឆ្នាំបន្ទាប់។

៣. ថ្នាក់ឆ្នាំទីបួន(ថ្នាក់បញ្ចប់បរិញ្ញាបត្រ) និស្សិតទទួលការណែនាំជាពិសេសដោយសង្កត់ធ្ងន់លើការបង្កើតស្នាដៃ ការបង្ហាញសមត្ថភាពតាមរយៈការប្រគំ ច្រៀង បញ្ជារវង់ភ្លេង ក៏ដូចជាការសិក្សាស្រាវស្រាវជ្រាវចងក្រងឯកសារ សម្រាប់ឡើងបង្ហាញស្នាដៃ និងការពារសារណានៅក្នុងពិធីប្រឡងបញ្ចប់បរិញ្ញាបត្រនាបំណាច់ឆ្នាំសិក្សានិមួយៗ។ ខាងក្រោមនេះគឺជាមុខវិជ្ជាតាមឆ្នាំនិមួយៗៈ

| **លេខកូដមុខវិជ្ជាឆ្នាំទី២** | (YEAR 2) | ***លេខកូដ*** *(CODE)* |
|---|---|---|
| ១.ឯកទេស* | Major Instruments or Study* | MUSIC201 |
| ២.អក្សរភ្លេង | Sol-fa | MUSIC216 |
| ៣.វិភាគតន្ត្រី | Musical Analysis | MUSIC205 |
| ៤.ជាតិពន្ធុតន្ត្រីវិទ្យា | Ethno-Musicology | MUSIC204 |
| ៥.អាម៉ូនី | Harmony | MUSIC206 |
| ៦.ប៉ូលីហ្វូនី | Counterpoint | MUSIC207 |

| | | |
|---|---|---|
| ៧.ប្រវត្តិតន្ត្រីបស្ចឹមប្រទេស | History of Western Music | MUSIC202 |
| ៨.កំណាព្យ(សម្រាប់អ្នកចម្រៀង) | Poem(Singer only) | MUSIC218 |
| ៩.ចរឹតឧបករណ៍តន្ត្រី | Instrumentation | MUSIC219 |
| ១០.អានបញ្ជារ៉េខា | Score Reading | MUSIC213 |
| ១២.ព្យាណូតម្រូវ/ព្យាណូអម | Class Piano/Collaborative Piano | MUSIC214 |
| ១៣.មុខវិជ្ជាជ្រើសរើស** | Elective Course** | MUSIC215 |
| ១៤.ភាសាអង់គ្លេស | English Language | MUSIC210 |
| ១៥.ប្រគំ | Orchestra | MUSIC221 |

| **លេខកូដមុខវិជ្ជាឆ្នាំទី៣** | (YEAR 3) | ***លេខកូដ*** *(CODE)* |
|---|---|---|
| ១.ឯកទេស* | Major Instruments or Study* | MUSIC301 |
| ២.អក្សរភ្លេង | Sol-fa | MUSIC316 |
| ៣.វិភាគតន្ត្រី | Musical Analysis | MUSIC305 |
| ៤.ជាតិពន្ធុតន្ត្រីវិទ្យា | Ethno-Musicology | MUSIC304 |
| ៥.អាម៉ូនី | Harmony | MUSIC306 |
| ៦.ប៉ូលីហ្វូនី | Counterpoint | MUSIC307 |
| ៧.ប្រវត្តិតន្ត្រីបស្ចឹមប្រទេស | History of Western Music | MUSIC302 |
| ៨.តន្ត្រីបុរាណ | Traditional Music | MUSIC303 |
| ៩.បញ្ជាវង់ភ្លេង | Conducting | MUSIC311 |
| ១០.ព្យាណូតម្រូវ/ព្យាណូអម | Class Piano/Collaborative Piano | MUSIC314 |
| ១១.មុខវិជ្ជាជ្រើសរើស | Elective Course | MUSIC315 |
| ១២.ភាសាអង់គ្លេស | English Language | MUSIC310 |
| ១៣.ប្រគំ | Orchestra | MUSIC321 |

| **លេខកូដមុខវិជ្ជាឆ្នាំទី៤** | (YEAR 4) | ***លេខកូដ*** *(CODE)* |
|---|---|---|
| ១.ឯកទេស* | Major Instruments or Study* | MUSIC401 |
| ២.គ្រប់គ្រងសិល្បៈ | Arts Management | MUSIC409 |
| ៣.សោភណ្ឌតន្ត្រី | Musical Aesthetic | MUSIC408 |

| | | |
|---|---|---|
| ៤.ប្រគំវង់តូច | Chamber Orchestra | MUSIC422 |
| ៥.ប្រគំ | Orchestra | MUSIC421 |
| ៦.វិធីសាស្ត្រស្រាវជ្រាវ | Research Method | MUSIC420 |
| ៧.ស្រាវជ្រាវ (ឯកទេសតន្ត្រីវិទ្យា) | Research Project | MUSIC424 |
| ៨.ប្រគំប្រឡងបញ្ចប់ | Recital | MUSIC425 |
| ៩.សារណា (ឯកទេសតន្ត្រីវិទ្យា) | Thesis | MUSIC426 |

* សូមមើលភាគឯកទេស

** សូមមើលតារាងមុខវិជ្ជាជ្រើស

## ៧. កិច្ចសហប្រតិបត្តិការជាមួយស្ថាប័នជាតិ និងអន្តរជាតិ

*មហាវិទ្យាល័យតូរ្យតន្ត្រីបានសហប្រតិបត្តិការណ៍ជាមួយនឹងស្ថាប័នជាតិ និងអន្តរជាតិនានាដើម្បីផ្លាស់ប្តូរបទពិសោធន៍លើវិស័យតូរ្យតន្ត្រី តាមរយៈសិក្ខាសាលា និងប្រគុំរួមគ្នាទាំងក្នុងប្រទេស និងក្រៅប្រទេស។*

*ក. កិច្ចសហប្រតិបត្តិការក្នុងប្រទេស៖*

*-ក្រសួងការបរទេស និងកិច្ចសហប្រតិបត្តិការអន្តរជាតិ*

*-ក្រសួងទេសចរណ៍*

*-ក្រសួងពត៌មាន*

*-សហភាពសហព័ន្ធយុវជនកម្ពុជា*

*-សាលាតូរ្យតន្ត្រីស៊ីមហ្វូនី* (SIMPHONY)

*-មជ្ឈមណ្ឌលវប្បធម៌កម្ពុជា-ជប៉ុន* (CJCC)

*-មជ្ឈមណ្ឌលវប្បធម៌ កម្ពុជា-កូរ៉េ* (CKCC)

*-អង្គការអម្រិតាសិល្បៈ*

*-អង្គការខ្មែរអមតៈ*

*-ស្ថានីយ៍ទូរទស្សន៍ជាតិ, បាយ័ន្ត, អាស៊ីអាគ្នេយ៍, ស៊ីធីអិន*

*-វិទ្យាស្ថានអន្តរជាតិភ្នំពេញ និងវិចិត្រសិល្បៈ* (PPIIA)

*-សាកលវិទ្យាល័យជាតិស៊ីហ្គាពួរ* (NATIONAL UNIVERSITY OF SIGAPOR )

*-ក្រសួងការបរទេសម៉ាឡេស៊ី* (MINISTRY OF FOREIGN AFFAIR OF MALAYSIA)

*- មូលនិធិតន្ត្រីដើម្បីទាំងអស់គ្នា*(M4ONE) *នៃសាធារណរដ្ឋកូរ៉េ*

*-ស្ថានទូតអាមេរិចប្រចាំប្រទេសកម្ពុជា* (USA EMBASSY)

***ខ. កិច្ចសហប្រតិបត្តិការក្រៅប្រទេស៖***

*- ប្រទេសជប៉ុន, សាធារណរដ្ឋប្រជាមានិតចិន, សាធារណៈរដ្ឋកូរ៉េ, ឥណ្ឌា, បារាំង, ហូឡង់, សង្ហ-បូរី, សហរដ្ឋអាមេរិច, ឥណ្ឌូណេស៊ី, ព្រះរាជណាចក្រថៃ, សាធារណរដ្ឋសង្គមនិយមវៀតណាម, អូស្ត្រាលី, ប៊្រុយណេ, សាធារណរដ្ឋប្រជាមានិតឡាវ ។ល។*

## ៨. លទ្ធផលដែលសម្រេចបាន

ចាប់តាំងពីឆ្នាំ១៩៨៨មក មហាវិទ្យាល័យតន្ត្រី បាននិងកំពុងបណ្តុះបណ្តាលនិស្សិតចំនួន១៦ជំនាន់ៗ ក្នុងនោះមានចំនួន១៣ជំនាន់ហើយដែលបានប្រឡងបញ្ចប់បរិញ្ញាបត្រតន្ត្រី មានឯកទេសដូចខាងក្រោម ៖

១. ឯកទេសឧបករណ៍តន្ត្រីបុរាណ ចំនួន១៧នាក់ (ស្ត្រី០២)

២. ឯកទេសចម្រៀងបុរាណ ចំនួន៥នាក់ (ស្ត្រី០៤)

៣. ឯកទេសឧបករណ៍តន្ត្រីបច្ចឹមប្រទេស ចំនួន៣៦នាក់ (ស្ត្រី១៥)

៤. ឯកទេសចម្រៀងជាពួក ចំនួន១៧នាក់ (ស្ត្រី០៧)

៥. ឯកទេសនិពន្ធតន្ត្រី ចំនួន៥ (ស្ត្រីគ្មាន)

៦. ឯកទេសបញ្ជាវង់ភ្លេង ចំនួន២នាក់ (ស្ត្រីគ្មាន)

៧.ឯកទេសតន្ត្រីវិទ្យា ចំនួន២៥នាក់ (ស្ត្រី០៨)

**សរុបចំនួន ១០៧ នាក់ (ស្ត្រី៣៦)**

និស្សិតដែលបានបញ្ចប់ការសិក្សាទាំងអស់ សុទ្ធតែទទួលបានការងារទាំងក្នុងក្រសួងស្ថាប័ន ជាតិ អង្គការក្រៅរាជរដ្ឋាភិបាល ក៏ដូចវិស័យឯកជនផងដែរ ដែលស្ទើរតែទាំងអស់សុទ្ធតែបានយក ជំនាញតន្ត្រីទៅប្រកបមុខរបរចិញ្ចឹមជីវិត តាមសមត្ថភាពរៀងៗខ្លួនដែលគួរជាទីមោទនៈៗ

ដោយឡែកក្នុងឆ្នាំសិក្សា២០១៤-២០១៥នេះនឹងមាននិស្សិតប្រឡងបញ្ចប់បរិញ្ញាបត្រជំនាន់ទី១៤ សរុបចំនួន១៥នាក់ (ស្ត្រី០៤) ដែលមានឯកទេសដូចខាងក្រោម ៖

១. ឯកទេសតន្ត្រីបុរាណ ចំនួន០៧នាក់ (ស្ត្រី០១)

២. ឯកទេសចម្រៀងបុរាណ ចំនួន០១នាក់ (ស្ត្រី០១)

៣. ឯកទេសតន្ត្រីបច្ចឹមប្រទេស ចំនួន០៥នាក់ (ស្ត្រី០២)

៤. ឯកទេសនិពន្ធតន្ត្រី ចំនួន០២ (ស្ត្រីគ្មាន)

## ១០. រូបថតសកម្មភាព





















